## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**
លេខ:...../.............

## សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិនៃសាធារណរដ្ឋប្រជាមានិតចិន គណប្រតិភូជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទដឹកនាំដោយ **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** នៃព្រះរាជាណាចក្រកម្ពុជានឹងចាកចេញដំណើរនៅវេលាម៉ោង៨:០០នាទី ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៦ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្នុងដំណើរទស្សនកិច្ចផ្លូវការរយៈពេល៥ថ្ងៃ នៅសាធារណរដ្ឋប្រជាមានិតចិន។

ក្នុងអំឡុងពេលបំពេញទស្សនកិច្ចរយៈពេល៥ថ្ងៃ ពីថ្ងៃទី៣០ ខែតុលា ដល់ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទៀ បាញ់** ព្រមទាំងគណប្រតិភូជាន់ខ្ពស់ក្រសួងការពារជាតិអញ្ជើញទៅចូលរួមទស្សនាការតាំងពិព័រណ៍លម្ហអាកាស និងអាកាសចរណ៍អន្តរជាតិលើកទី១១ នៅ ZhuHai នៃសាធារណរដ្ឋប្រជាមានិតចិន ហើយគណប្រតិភូនឹងអញ្ជើញមកដល់ព្រះរាជាណាចក្រកម្ពុជា នៅម៉ោងប្រមាណ 23:00 ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦